# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
# ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
# សិក្ខាសាលាជាមួយគ្រូបង្រៀន-ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
# ព្រះវិហារ ថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១០

## គោលបំណង

ក្នុងខែធ្នូឆ្នាំ២០១០មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡានឹងរៀបចំកិច្ចប្រជុំការងារជាមួយលោកគ្រូអ្នកគ្រូប្រចាំឆ្នាំលើកទីពីររបស់ខ្លួនក្នុងខេត្តព្រះវិហារ ក្នុងគោលបំណងបង្កើតឡើងនូវក្រុមការងារមួយ ដើម្បីចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជារយៈដំណើរការស្វែងរកការពិត និងផ្សះផ្សា និងពង្រឹងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ អ្នកចូលរួមនៅក្នុងសិក្ខាសាលានេះរួមមានគ្រូបង្គោលថ្នាក់ជាតិចំនួន២៣រូប និងគ្រូបង្គោលថ្នាក់ខេត្តចំនួន១៨០រូប ដែលបានទទួលការបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅពាក់កណ្តាលនិងចុងឆ្នាំ២០០៩បន្តបន្ទាប់គ្នា ។ សិក្ខាសាលានេះនឹងផ្តោតការពិភាក្សាទៅលើប្រធានបទសំខាន់ៗចំនួន៤គឺ ៖

### ការបង្កើតក្រុមការងារមួយសម្រាប់ចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យៈ

មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ដំណើរការនៃការស្វែងរកការពិតនិងផ្សះផ្សារមួយ ដែលស្របទៅនឹងបរិបទសង្គមនិងវប្បធម៌របស់កម្ពុជា គួរតែត្រូវបានបង្កើតឡើង ដើម្បីជំរុញដល់ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការផ្សះផ្សាជាតិ និងដើម្បីចងក្រងឯកសារទាក់ទងទៅនឹងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គម្រោងសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ អាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់ការបង្កើតគណៈកម្មាធិការស្វែងរកការពិត និងផ្សះផ្សាជាផ្លូវការនិងទូលំទូលាយមួយនៅក្នុងថ្ងៃអនាគត ។ ក្រសួងអប់រំបានលើកឡើងថា គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ខេត្តរបស់ក្រសួងអប់រំយុវជននិងកីឡាអាចដើរតួនាទីក្នុងការប្រមូលចងក្រង និងចែកចាយព័ត៌មានប្រវត្តិសាស្ត្រស្តីអំពីរបបខ្មែរក្រហម ។ ទម្រង់ដ៏ត្រឹមត្រូវមួយនៅក្នុងការប្រមូលនិងចងក្រងព័ត៌មានទាំងនេះ នឹងត្រូវបានកំណត់អាស្រ័យទៅតាមការបង្ហាញពីចំណង់ចំណូលចិត្តរបស់ជនរងគ្រោះដោយអនុលោមទៅតាមបរិបទវប្បធម៌របស់កម្ពុជា ។ ជាបឋម ដំណើរការស្វែងរកការពិត និងយុត្តិធម៌នៅកម្ពុជាមានលក្ខណៈជាការអប់រំនៅក្នុងការចែកចាយព័ត៌មានក្នុងលក្ខណៈដែល

អាចស្វែងរកបាន និងការជីកគាស់នូវព័ត៌មានទាំងឡាយស្តីអំពីរបបខ្មែរក្រហមដែលមានវិសាលភាពហួសពីដែនកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រុមការងារ ស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងធ្វើការពិភាក្សា និងបង្កើតឡើងនូវដែនកំណត់នៃដំណើរការស្វែងរកយុត្តិធម៌ និងផ្សះផ្សា ។ (ឆាំង យុ និងអ្នកជំនាញអន្តរជាតិ)

**ការអភិវឌ្ឍន៍ជំនាញៈ** សិក្ខាសាលានេះនឹងផ្តោតទៅលើការពង្រឹងសមត្ថភាពរបស់គ្រូបង្គោលថ្នាក់ជាតិ និងគ្រូបង្គោលថ្នាក់ខេត្ត ដែលជាគ្រូខ្ទេសនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន លើកក្រោយៗទៀត ។ នៅក្នុងឆ្នាំ២០១១និងឆ្នាំបន្តបន្ទាប់ទៀត មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំយុវជន និងកីឡា និងបន្តផ្តល់ការបណ្តុះបណ្តាលដល់គ្រូមុខវិជ្ជាប្រវត្តិវិទ្យា ដែលនៅសេសសល់ និងលោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវិជ្ជាភាសារខ្មែរនិងសីលធម៌ពលរដ្ឋ ។ វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានចំនួន៣លើក កន្លងមកបានបង្ហាញឲ្យឃើញថាសមត្ថភាពរបស់គ្រូបង្គោលថ្នាក់ជាតិនិងគ្រូបង្គោលថ្នាក់ខេត្ត នៅក្នុងការពន្យល់អំពីវិធីសាស្ត្របង្រៀនទៅគ្រូថ្នាក់មូលដ្ឋាននៅមានកម្រិត ។ នៅក្នុងករណីមួយចំនួនគ្រូបង្គោលថ្នាក់ជាតិ និងគ្រូបង្គោលថ្នាក់ខេត្តមានគំនិតផ្ទុយគ្នាទៅលើជំហាននៃវិធីសាស្ត្រនីមួយៗ ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះសិក្ខាសាលានឹងពិនិត្យមើលឡើងវិញនូវខ្លឹមសារទាំងមូលនៅក្នុងសៀវភៅណែនាំគ្រូជាមួយនឹងគ្រូបង្គោលថ្នាក់ជាតិនិងគ្រូបង្គោលថ្នាក់ខេត្តទាំងអស់ និងពិភាក្សាលម្អិតទៅលើខ្លឹមសារ នៃវិធីសាស្ត្រនីមួយៗ ។ (គ្រីស ឌៀរីង និង ស៊ីរ៉ិ សាវីណា)

**ប្រសិទ្ធភាពនៃការបង្រៀន** ៖ សិក្ខាសាលានេះនឹងពិភាក្សា ថាតើគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀនដោយរបៀបណា ។ សំណួរចម្បងៗមួយចំនួន នឹងត្រូវលើកយកមកពិភាក្សា ។ តើគ្រូអាចយកចំណេះដឹង ជំនាញ និងវិធីសាស្ត្រដែលខ្លួនទទួលបានពីវគ្គបណ្តុះបណ្តាល ទៅអនុវត្តនៅក្នុងថ្នាក់រៀនបានដែរឬទេ? តើគ្រូអាចបង្រៀនមេរៀននៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀនបានចំនួនប៉ុន្មាន? តើគ្រូអាចអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធិភាពនៅក្នុងបរិបទនៃបរិស្ថានក្នុងថ្នាក់រៀនរបស់ខ្លួនបានដែរឬទេ? តើបញ្ហាប្រឈមអ្វីខ្លះដែលគ្រូបានជួបប្រទះនៅក្នុងកំឡុងពេលនៃការបង្រៀននៅក្នុងការអនុវត្តនូវវិធីសាស្ត្រថ្មីនិងសម្ភារខបទ្ទេស ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឲ្យ? ទោះបីជាគ្រូបង្គោលថ្នាក់ជាតិនិងគ្រូបង្គោលថ្នាក់ខេត្ត បានឆ្លងកាត់នូវវគ្គបណ្តុះបណ្តាលរួចហើយក្តី ក៏គ្រូទាំងអស់នូវមានការខ្វល់ខ្វាយមួយចំនួនដែលមិនត្រឹមតែទាក់ទងនឹងបញ្ហាសង្គមនិងសីលធម៌ប្រកបដោយភាពស្មុគស្មាញនិងធម្មជាតិ នៃភាពរសើបផ្នែកនយោបាយ នៃការ

បង្រៀនប្រវត្តិសាស្រ្តខ្មែរក្រហមតែប៉ុណ្ណោះទេ ថែមទាំងទាក់ទងទៅនឹងសមត្ថភាពនៅក្នុងការបង្រៀនប្រវត្តិសាស្រ្តនេះប្រកបដោយប្រសិទ្ធិភាព។ សិក្ខាសាលានេះនឹងផ្តល់នូវឧបករណ៍ទាំងឡាយដើម្បីពង្រឹងប្រសិទ្ធិភាពក្នុងការបង្រៀន។ (ជា ផល្លា និង ឌីខាំ បូលី)

**ការចងក្រងរឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិត** ៖ នៅក្នុងតួនាទីរបស់ខ្លួនក្នុងនាមជាសមាជិកក្រុមការងារ គ្រូបង្គោលថ្នាក់ជាតិនិងគ្រូបង្គោលថ្នាក់ខេត្តទាំងអស់ នឹងមានកាតព្វកិច្ចបន្ថែមទៀត។ គ្រូបង្គោលទាំងអស់ មិនមែនមានតួនាទីត្រឹមតែអប់រំសិស្សអំពីប្រវត្តិសាស្រ្តខ្មែរក្រហមប៉ុណ្ណោះទេថែមទាំងមានតួនាទីជំរុញសិស្សទាំងអស់ ឲ្យធ្វើការចងក្រងនូវរឿងរ៉ាវ របស់ឪពុកម្តាយ ជីដូនជីតាសាច់ញាតិ និងអ្នកជិតខាង ដើម្បីថែរក្សាការចងចាំពីអំពើហឹង្សានៅក្នុងអតីតកាល ដែលជាផ្នែកមួយនៃដំណើរការស្វែងរកការពិតនិងផ្សះផ្សា។ គ្រូនឹងដើរតួនាទីចម្បងនៅក្នុងការប្រមូលនិងចងក្រងនូវរឿងរ៉ាវទាំងអស់តាមភូមិឋានដែលខ្លួនរស់នៅ ឬកំពុងបង្រៀន ដែលរឿងរ៉ាវទាំងនេះនឹងត្រូវបានបោះពុម្ពជាសៀវភៅរៀងរាល់ឆ្នាំ។ គ្រូបង្គោលថ្នាក់ខេត្តម្នាក់ៗ ដែលមកពីតាមបណ្តាស្រុកទាំងអស់ នៅក្នុងប្រទេសកម្ពុជា ត្រូវសរសេរសាច់រឿងដែល អាចបោះពុម្ពបានចំនួនបី ដែលមានប្រវែងយ៉ាងតិចបំផុត ១០ទំព័រសរសេរដោយដៃ។ តាមរយៈវិធីសាស្រ្តនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអាចបោះពុម្ពផ្សាយរឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិតចំនួន៥៤០នាក់ក្នុងមួយឆ្នាំ។ រឿងរ៉ាវទាំងនេះនឹងផ្តល់ចម្លើយច្បាស់លាស់មួយទៅនឹងសំណួរដែលថា ហេតុអ្វីបានជាខ្មែរក្រហមប្រព្រឹត្តអំពើឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ របៀបនេះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។ រឿងរ៉ាវទាំងនេះក៏នឹងធ្វើការបកស្រាយឲ្យកាន់តែច្បាស់លាស់បន្ថែមទៀតនូវកត្តាដែលនាំទៅដល់ការរៀបចំឡើងនូវអំពើឧក្រិដ្ឋទាំងនេះ។ សរុបបញ្ចូលគ្នាមករឿងរ៉ាវទាំងនេះនឹងផ្តល់ឲ្យនូវការពណ៌នាយ៉ាងទូលំទូលាយទៅលើរូបភាពទាំងមូលនៃប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ។ (សូ ហ្វារីណា កែវ ដាសុីល និង ភីជី ម៉ាក់វ៉ាយអឺរ)

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង អេង កុកថាយ តាមរយៈទូរស័ព្ទលេខ ៖ ០១២ ៩៥ ៥៨ ៥៨